# កម្មវិធីអាហារូបត្ថម្ភនៃអង្គការសហប្រជាជាតិ (UNN) នៅកម្ពុជា៖ កំណើនថ្លៃម្ហូបអាហារបង្កហានិភ័យដល់សន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា


រូបថត៖ WHO/Cambodia

**ក្រៅពីភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ចសង្គមដែលកើតឡើងដោយសារជំងឺកូវីដ-១៩ និងបាតុភូតអាកាសធាតុនានា (UNICEF & WFP 2021) ប្រទេសកម្ពុជាកំពុងប្រឈមនឹងការគំរាមកំហែងថ្មីមួយចំពោះសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដោយសារថ្លៃស្បៀងអាហារក្នុងស្រុក និងក្នុងពិភពលោកកំពុងកើនឡើងយ៉ាងឆាប់រហ័ស។** ថ្នាក់ដឹកនាំនៅទូទាំងពិភពលោក និងទីភ្នាក់ងារអង្គការសហប្រជាជាតិ បានចាប់ផ្តើមប្រកាសនូវសញ្ញាអាសន្នអំពីវិបត្តិស្បៀងអាហារពិភពលោកដែលកំពុងតែខិតមកជិតដល់។ នៅក្នុង សេចក្តីថ្លែងការណ៍ កាលពីខែឧសភា លោក António Guterres អគ្គលេខាធិការនៃអង្គការសហប្រជាជាតិបានព្រមានថា «កម្រិតនៃភាពអត់ឃ្លានជាសកលកំពុងកើនដល់កម្រិតខ្ពស់ថ្មីមួយ។» «ក្នុងរយៈពេលត្រឹមតែពីរឆ្នាំប៉ុណ្ណោះ ចំនួនមនុស្សដែលជួបបញ្ហាអសន្តិសុខស្បៀងធ្ងន់ធ្ងរបានកើនឡើងទ្វេដង ពី១៣៥លាននាក់ មុនការរាតត្បាតនៃជំងឺកូវីដ ១៩ រហូតដល់ ២៧៦លាននាក់គិតត្រឹមថ្ងៃនេះ... ប្រសិនបើយើងមិនដោះស្រាយបញ្ហានេះនៅថ្ងៃនេះទេ យើងនឹងប្រឈមនឹងគ្រោះខ្វះខាតស្បៀងជាសាកលក្នុងរយៈពេលប៉ុន្មានខែខាងមុខនេះ។»

**នៅកម្ពុជា ការកើនឡើងនូវថ្លៃស្បៀងអាហារផលិតក្នុងស្រុកដោយសារការកើនឡើងថ្លៃប្រេងឥន្ធនៈ ថ្លៃដឹកជញ្ជូន និងថ្លៃនៃធាតុចូលផ្នែកកសិកម្ម ដូចជាជី ជាដើម គឺជាក្តីកង្វល់ដ៏ធំមួយចំពោះសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ជាពិសេសសម្រាប់ក្រុមជនងាយរងគ្រោះបំផុត។** បើទោះបីជាថ្លៃអង្ករ ដែលជាស្បៀងចម្បងនៅក្នុងរបបអាហាររបស់ប្រជាជនកម្ពុជា មិនមានការប្រែប្រួលច្រើនក្តីរយៈពេលកន្លងមក ក៏ប៉ុន្តែសហព័ន្ធស្រូវអង្ករកម្ពុជាព្យាករណ៍ថា វាអាចនឹងកើនឡើងពី១០%ទៅ២០% ក្នុងរយៈពេលប៉ុន្មានខែខាងមុខនេះ ដោយសារតែការកើនឡើងនូវថ្លៃនៃធាតុចូលសម្រាប់ផលិតអង្ករ (CRF 2022)។ ក្រៅពីនេះ តម្លៃអាហារសម្បូរជីវជាតិដែលគេនិយមទទួលទានដូចជា ស៊ុតទា និងត្រកួនបានកើនឡើងដល់ទៅ២០.៨% និង៣០.៧% ក្នុងខែឧសភា ឆ្នាំ២០២២ បើធៀបនឹងអំឡុងពេលដូចគ្នាកាលពីឆ្នាំមុន (WFP, 2022)។ **ថ្លៃអាហារនាំចូលក៏មានការកើន**

**ឡើងយ៉ាងខ្ពស់ផងដែរ។** តម្លៃប្រេងឆាកើនឡើង៣៩.៧% ក្នុងខែឧសភា ឆ្នាំ២០២២ ធៀបនឹងខែឧសភា ឆ្នាំ២០២១ ហើយកំណើននេះបានកើនឡើង (១៣.៥%) តាំងពីខែកុម្ភៈ ឆ្នាំ២០២២ (WFP, 2022)។

**នៅឆ្នាំ២០១៧ មុនពេលមានវិបត្តិជាបន្តបន្ទាប់ ប្រជាជនកម្ពុជាម្នាក់ក្នុងចំណោមប្រាំនាក់ – តំបន់ខ្លះ មានពីរនាក់ក្នុងចំណោមបីនាក់ – ពុំមានលទ្ធភាពទិញរបបអាហារសម្បូរជីវជាតិ ដែលមានតម្លៃទាបជាងគេឡើយ (CARD & WFP, 2017)**។ ហេតុដូច្នេះ កុមារមួយចំនួនធំនៅកម្ពុជា មិនបានទទួលសារជាតិចិញ្ចឹមចាំបាច់ក្នុងបរិមាណគ្រប់គ្រាន់ ដែលមានប្រភពពីផ្លែឈើ បន្លែ និងសត្វឡើយ។ បន្ទាប់ពីមានការរាតត្បាតនៃជំងឺកូវីដ១៩ នៅកម្ពុជា មានគ្រួសារជាច្រើនបានលើកឡើងថា ជាការឆ្លើយតបទៅនឹងបញ្ហាកង្វះអាហារ ពួកគាត់បានប្តូរទៅទទួលទាបអាហារដែលមានតម្លៃថោក ហើយមានគ្រួសារជាងពាក់កណ្តាលបានកាត់បន្ថយបរិមាណអាហារ និងបន្ថយការទទួលទានប្រភេទអាហារដែលសម្បូរប្រូតេអ៊ីន វីតាមីនអា និងជាតិដែក។ គួរកត់សម្គាល់ថា ស្ត្រីដែលទទួលបានជីវជាតិពីអាហារគ្រប់គ្រាន់តាមបទដ្ឋានរបបអាហារចម្រុះអប្បបរមា បានធ្លាក់ចុះពី៦៨%មកនៅ៥៥% គិតត្រឹមខែធ្នូ ឆ្នាំ២០២១ (របបអាហារចម្រុះអប្បបរមាសំដៅដល់ការទទួលទានអាហារយ៉ាងតិចឱ្យបាន៥ក្រុម ក្នុងអំឡុងពេល២៤ម៉ោងមុន) (UNICEF & WFP 2021)។ ក្នុងខណៈពេលដែលតម្លៃអាហារសម្បូរជីវជាតិនៅលើទីផ្សារមានការកើនឡើងខ្ពស់លើសពីលទ្ធភាពរបស់ប្រជាជនជាច្រើននូវទូទាំងប្រទេស គេរំពឹងថាការទទួលទានរបបអាហារសុខភាពនឹងបន្តធ្លាក់ចុះថែមទៀត។ ចំនុចនេះគឺជាក្តីបារម្ភជាពិសេសសម្រាប់ក្រុមគ្រួសារក្រីក្រ ដែលបានចំណាយថវិកាមួយផ្នែកធំនៃចំណូលរបស់គាត់ទៅលើអាហាររួចហើយ ពីព្រោះពួកគាត់នឹងរងផលប៉ះពាល់ក្នុងកម្រិតធ្ងន់ធ្ងរជាងគេ ដោយសារតែការកើនឡើងនៃតម្លៃម្ហូបអាហារសម្បូរជីវជាតិ។ ទន្ទឹមនឹងនោះ ការកើនឡើងនូវថ្លៃម្ហូបអាហារ អាចបណ្តាលឱ្យប្រជាជនងាកទៅរកការទទួលទានកាន់តែច្រើននូវអាហារដែលមិនល្អសម្រាប់សុខភាព អាហារដែលមានកែច្នៃក្នុងកម្រិតខ្ពស់ ដោយសារតែអាហារទាំងនេះមានតម្លៃថោក ងាយស្រួលរកបាន និងងាយធ្វើទីផ្សារជាងអាហារដទៃទៀត។

**នៅខណៈនេះអាហារូបត្ថម្ភមានសារៈសំខាន់ជាងពេលណាៗទាំងអស់ ជាពិសេសសម្រាប់កុមារតូច។** កំណើនតម្លៃអាហារទំនងជានឹងបង្កឱ្យបញ្ហាកង្វះអាហារូបត្ថម្ភរបស់កុមារកាន់តែធ្ងន់ធ្ងរឡើង ខណៈពេលដែលកម្ពុជាទើបចាប់ផ្តើមស្តារសេដ្ឋកិច្ចឡើងវិញពីផលប៉ះពាល់ដោយសារជំងឺរាតត្បាត។ ទិន្នន័យបឋមពីការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជាឆ្នាំ២០២១-២០២២ បង្ហាញថា ភាពក្រិសក្រិន(កង្វះអាហារូបត្ថម្ភរ៉ាំរ៉ៃ) ក្នុងចំណោមកុមារអាយុក្រោម៥ឆ្នាំ បានថយចុះពី៣២% ក្នុងឆ្នាំ២០១៤ មកត្រឹម២២% ដែលជាអត្រាវឌ្ឍនភាពដែលលើសពីគោលដៅ។ ប៉ុន្តែកុមារអាយុក្រោម៥ឆ្នាំចំនួន១០%នៅតែមានភាពស្គមស្គាំង (កង្វះអាហារូបត្ថម្ភស្រួចស្រាវ) ដែលអត្រានេះនៅពុំទាន់មានការផ្លាស់ប្តូរទេក្នុងទសវត្សរ៍កន្លងមក។ នៅក្នុងខេត្តមួយចំនួន អត្រានៃភាពស្គមស្គាំងមានច្រើនជាង១៥% ដែលខ្ពស់ជាងកម្រិតអាសន្នដែលត្រូវសង្គ្រោះបន្ទាន់។ ស្របពេលជាមួយគ្នានោះដែរ កុមារលើសទម្ងន់និងធាត់ជ្រុលកើនឡើងទ្វេដងក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ។ អាហារូបត្ថម្ភល្អមានសារៈសំខាន់ណាស់ក្នុងការជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចរយៈពេលវែង ពីព្រោះវាមានផលជះវិជ្ជមានទៅលើធនធានមនុស្ស ដូចមានបង្ហាញនៅក្នុងការសិក្សាអំពី «ផលវិបាកសេដ្ឋកិច្ចនៃកង្វះអាហារូបត្ថម្ភនៅកម្ពុជា» (CARD, UNICEF & WFP, 2013) ដែលប៉ាន់ប្រមាណថា ការខាតបង់សេដ្ឋកិច្ចប្រចាំឆ្នាំ

ដោយសារបញ្ហាអាហារូបត្ថម្ភនៅកម្ពុជាមានចន្លោះពី២៥០ទៅ៤០០លានដុល្លារអាមេរិក ស្មើនឹង១.៥ ទៅ ២.៥% នៃផលិតផលក្នុងស្រុកសរុប។

**ក៏ប៉ុន្តែ មូលនិធិដើម្បីប្រយុទ្ធប្រឆាំងនឹងបញ្ហាអាហារូបត្ថម្ភរាល់គ្រប់ទម្រង់ មិនទាន់គ្រប់គ្រាន់ទៅតាមទំហំនៃតម្រូវការនោះទេ។** នេះជាការពិតដូចដែលបង្ហាញតាមរយៈបរិមាណថវិកាសម្រាប់អាហារូបត្ថម្ភដែលត្រូវបានអនុម័តនៅក្នុងវិស័យនានាដូចជា វិស័យកិច្ចគាំពារសង្គម វិស័យសុខភិបាល វិស័យអប់រំ វិស័យកសិកម្ម វិស័យទឹក និងអនាម័យ។ ជាឧទាហរណ៍ ផែនទីបង្ហាញផ្លូវផែនការសកម្មភាពជាតិសម្រាប់ការបង្ការ និងព្យាបាលកុមារស្គមស្គាំង ប៉ាន់ប្រមាណថា នឹងត្រូវការថវិកាចំនួន២៥លានដុល្លារសម្រាប់រយៈពេល៣ឆ្នាំខាងមុខ ដើម្បីបំពេញតម្រូវការចាំបាច់ និងឆ្លើយតបទៅនឹងបញ្ហាកង្វះអាហារូបត្ថម្ភស្រួចស្រាវ។ ប៉ុន្តែបច្ចុប្បន្នយើងមានថវិកាត្រឹមតែ៣១%ប៉ុណ្ណោះ នៅខ្វះខាតចំនួន១៧.២លានដុល្លារទៀត។

**កម្មវិធីអាហារូបត្ថម្ភនៃអង្គការសហប្រជាជាតិ សូមស្នើនូវអនុសាសន៍ដូចខាងក្រោម** ដើម្បីធានាថាចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដែលរំលេចឡើងតាមរយៈគោលនយោបាយ យុទ្ធសាស្ត្រ និងការប្តេជ្ញាចិត្តប្រកបដោយមហិច្ឆិតា នៅក្នុងកិច្ចប្រជុំកំពូលស្តីពីប្រព័ន្ធស្បៀង និងកិច្ចប្រជុំកំពូលដើម្បីលើកកម្ពស់អាហារូបត្ថម្ភឆ្នាំ២០២១ នឹងអាចសម្រេចទៅបាន។

*សកម្មភាពអាទិភាពក្នុងរយៈពេលខ្លី៖*

- **បង្កើនការគាំទ្រហិរញ្ញវត្ថុលើផ្នែកអាហារូបត្ថម្ភ ដោយផ្តោតជាពិសេសលើកុមារ។** ដើម្បីធានាថាកម្ពុជាសម្រេចគោលដៅសន្តិសុខស្បៀង និងអាហារូបត្ថម្ភរបស់ខ្លួន ចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងក្នុងការបង្កើននូវថវិកាសម្រាប់អាហារូបត្ថម្ភក្នុងស្រុក ដែលទទួលបានពីប្រភពជាសាធារណៈ និងឯកជន និងក្នុងពេលដំណាលគ្នាកៀរគរធនធានខាងក្រៅបន្ថែម។ ក្នុងអំឡុងពេលឆាប់ៗ រដ្ឋាភិបាល រួមជាមួយនឹងម្ចាស់ជំនួយ និងភាគីពាក់ព័ន្ធផ្សេងទៀត ត្រូវតែប្តេជ្ញាផ្តល់អាទិភាពដល់ធនធានសម្រាប់ធានាការបម្រុងទុកគ្រប់គ្រាន់នូវ អាហារព្យាបាល (ready-to-use therapeutic foods) សម្រាប់ប្រើប្រាស់ដើម្បីសង្គ្រោះជីវិតកុមារដែលខ្វះអាហារូបត្ថម្ភធ្ងន់ធ្ងរ។ នេះគឺជាចំណុចដ៏សំខាន់ ពីព្រោះគេរំពឹងថា ថ្លៃរបស់ទំនិញសង្គ្រោះជីវិតទាំងនេះ នឹងកើនឡើង ១៦% ក្នុងរយៈពេលប្រាំមួយខែខាងមុខ ដោយសារតែវិបត្តិពិភពលោក។ ក្រៅពីនេះ រដ្ឋាភិបាលត្រូវតែធានាថា ការកើនឡើងថ្លៃម្ហូបអាហារមិនប៉ះពាល់ដល់គុណភាពអាហារដែលផ្តល់តាមរយៈកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់ស្បៀងក្នុងមូលដ្ឋានឡើយ។ ករណីនេះអាចសម្រេចបានតាមរយៈការតាមដានត្រួតពិនិត្យតម្លៃម្ហូបអាហារ និងកំណត់កម្រិតនៃការកើនឡើងដែលត្រូវបន្ថែមថវិការសម្រាប់របបអាហារ។
- **ពង្រឹងកម្មវិធីជំនួយជាសាច់ប្រាក់ ជាយន្តការគាំពារសង្គមដ៏សំខាន់ ដើម្បីកាត់បន្ថយផលប៉ះពាល់រយៈពេលខ្លី លើក្រុមជនងាយរងគ្រោះបំផុត។** ជាមួយនឹងកំណើនតម្លៃម្ហូបអាហារ ក្រុមគ្រួសារកាន់តែច្រើននឹងពុំមានលទ្ធភាពទិញអាហារមានជីវជាតិបានទេ។ កិច្ចគាំពារសង្គមតាមរយៈជំនួយជាសាច់ប្រាក់ក្នុងបរិមាណគ្រប់គ្រាន់ អាចជួយលើកកម្ពស់លទ្ធភាពពួកគាត់ និងធានា

ថាពួកគាត់ទទួលបានអាហារក្នុងបរិមាណ និងគុណភាពគ្រប់គ្រាន់ ជាពិសេសសម្រាប់ក្រុមជនងាយរងគ្រោះ ដូចជា ស្ត្រីមានផ្ទៃពោះ និងកុមារតូច។ អាហារដែលលើកកម្ពស់អាហារូបត្ថម្ភសមស្របគឺជាប្រភេទអាហារដែលសម្បូរទៅដោយជាតិប្រូតេអ៊ីន វីតាមីន និងសារធាតុរ៉ែ ដែលមានដូចជាសាច់ ស៊ុត ត្រី ផលិតផលទឹកដោះសត្វ បន្លែស្លឹកបៃតង ពពួកសណ្តែក ផ្លែឈើសាច់ពណ៌ទឹកក្រូច និងបន្លែផ្សេងៗ ដែលអាហារទាំងអស់នេះភាគច្រើនមានតម្លៃថ្លៃជាងពពួកអាហារដែលផ្សំពីអង្ករ។

- **សិក្សាស្វែងយល់អំពីលទ្ធភាពទិញ ការទទួលបានរបបអាហារសុខភាព និងកត្តាបង្កបញ្ហា អាហារូបត្ថម្ភ។** ការបន្តតាមដាន និងវិភាគមានសារៈសំខាន់ណាស់ ដើម្បីស្វែងយល់ថាតើការប៉ះទង្គិចទ្រង់ទ្រាយធំ ដូចជាវិបត្តិកំណើនតម្លៃស្បៀងអាហារ មានការប៉ះពាល់ដូចម្តេចខ្លះទៅលើសន្តិសុខស្បៀង និងអាហារូបត្ថម្ភរបស់ប្រជាជនកម្ពុជា។ ដើម្បីធានាថាយើងនឹងមិនទុកនរណាម្នាក់នៅក្រោយការអភិវឌ្ឍន៍ និងដើម្បីឱ្យការត្រួតពិនិត្យតាមដានមានប្រសិទ្ធិភាពពេញលេញ វាជាការចាំបាច់ដែលការកំណត់គោលដៅត្រូវមានបរិយាប័ន្ន និងគ្រប់ជ្រុងជ្រោយ ដោយផ្តោតការយកចិត្តទុកដាក់លើ ភាពងាយរងគ្រោះក្រប់ទម្រង់ រួមទាំងភាពងាយរងគ្រោះដែលពាក់ព័ន្ធជាមួយនឹងអាយុ ភេទ និងពិការភាពផងដែរ។ លទ្ធផលនៃការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជាដែលបានបង្ហាញថ្មីៗនេះ ផ្តល់នូវឱកាសក្នុងការវិភាគបន្ថែមអំពីកត្តាបង្កបញ្ហាអាហារូបត្ថម្ភ។ ព័ត៌មានទាំងនេះនឹងជួយក្នុងការធ្វើផែនការសកម្មភាពឱ្យកាន់តែមានប្រសិទ្ធភាព និងឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋ ជាពិសេសក្រុមជនក្រីក្រ និងងាយរងគ្រោះបំផុត។

*សកម្មភាពអាទិភាពក្នុងរយៈពេលមធ្យមៈ*

- **ចាំបាច់ត្រូវធានាថា សារអំពីអាហារូបត្ថម្ភដែលផ្ញើរមជាមួយនឹងការផ្ទេរសាច់ប្រាក់ និងអាហារសុខភាពត្រូវបានផ្សព្វផ្សាយតាមរយៈយុទ្ធនាការផ្លាស់ប្តូរទម្លាប់សង្គមប្រកបដោយប្រសិទ្ធភាព។** ផលជះវិជ្ជមាននៃកម្មវិធីផ្ទេរសាច់ប្រាក់នឹងកាន់តែធំ នៅពេលដែលវាត្រូវបានភ្ជាប់ជាមួយនឹងសារអំពីអាហារូបត្ថម្ភល្អ។ ដូច្នេះ ការលើកកម្ពស់អាហារូបត្ថម្ភស្របពេលជាមួយនឹងការផ្ទេរសាច់ប្រាក់ តាមរយៈការបង្ហាញសារអាហារូបត្ថម្ភរួមជាមួយនឹងការជូនដំណឹងអំពីការផ្ទេរប្រាក់ ឬនៅតាមកន្លែងផ្ទេរប្រាក់ មានសារៈសំខាន់ណាស់ក្នុងការកែលម្អទម្លាប់ទទួលទានអាហារ។ សារទាំងនេះមានសារៈសំខាន់ណាស់ក្នុងការផ្តល់ព័ត៌មាន និងការណែនាំអំពីរបៀបចាយប្រាក់ត្រឹមត្រូវដើម្បីទិញអាហារសម្បូរជីវជាតិ ជាពិសេសសម្រាប់ស្ត្រីមានផ្ទៃពោះនិងបំបៅដោះកូន និងកុមារតូច។ យុទ្ធនាការផ្លាស់ប្តូរទម្លាប់សង្គមដែលមានប្រសិទ្ធភាព ចាំបាច់ត្រូវតែជាកិច្ចការអាទិភាព ដើម្បីធានាថា ក្រុមគ្រួសារ និងអាណាព្យាបាលមានជំនាញ និងសមត្ថភាពក្នុងការទទួលយកនិងការអនុវត្តទម្លាប់រស់នៅដើម្បីសុខភាពល្អ។
- **បង្កើនការប្រើប្រាស់ធនធាននៅគ្រប់កម្រិត និងក្នុងអន្តរវិស័យ។** ការដោះស្រាយបញ្ហាជាប់គាំង និងបញ្ហានានានៅក្នុងប្រព័ន្ធស្បៀងនៅកម្ពុជាប្រកបដោយប្រសិទ្ធភាព ទាមទារឱ្យមានការ

បង្កើនការសម្របសម្រួល និងកិច្ចសហការនៅគ្រប់កម្រិត។ ដើម្បីគាំទ្រដល់ប្រសិទ្ធិភាពនិងចីរភាពនៃហិរញ្ញប្បទានសម្រាប់ការលើកកម្ពស់វិស័យស្បៀងនិងអាហារូបត្ថម្ភ ប្រព័ន្ធសម្របសម្រួលថ្នាក់ក្រោមជាតិសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភដែលបានបង្កើតឡើងនៅក្រោមយុទ្ធសាស្ត្រជាតិសន្តិសុខស្បៀង និងអាហារូបត្ថម្ភ (២០១៩-២០២៣) ដំណាក់កាលទី២ អាចគួរត្រូវយកមកប្រើប្រាស់ដើម្បីពង្រឹងសមត្ថភាពតួអង្គពាក់ព័ន្ធនៅគ្រប់កម្រិត។ ការធ្វើបែបនេះនឹងជួយក្នុងការដាក់បញ្ចូលបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភទៅក្នុងផែនការ និងថវិកាមូលដ្ឋាន។

*សកម្មភាពអាទិភាពក្នុងរយៈពេលវែង៖*

- **បង្កើនប្រសិទ្ធភាពខ្សែច្រវាក់តម្លៃ ដើម្បីធានាកាត់បន្ថយឥទ្ធិពលរបស់វិបត្តិនាពេលអនាគតទៅលើសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។** ចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងដើម្បីគាំទ្រសមត្ថភាពកសិករខ្នាតតូច សហគ្រាសធុនតូចនិងមធ្យម និងអង្គការសង្គមស៊ីវិលក្នុងស្រុក ដើម្បីបន្តផលិត និងចែកចាយអាហារចម្រុះដែលមានតម្លៃសមរម្យ ក្នុងបរិមាណគ្រប់គ្រាន់ មានសុវត្ថិភាព និងសមស្របទៅតាមវប្បធម៌។ កិច្ចការនេះគួរត្រូវបានបំពេញបន្ថែមជាមួយនឹងការខិតខំប្រឹងប្រែងគៀរគរការគាំទ្រពីវិស័យឯកជនក្នុងការវិនិយោគលើវិស័យអាហារូបត្ថម្ភតាមរយៈការបញ្ចូលមីក្រូសារជាតិទៅក្នុងអាហារគោល ការកាត់បន្ថយសំណល់ និងការបាត់បង់ស្បៀង និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធបៃតង តាមរយៈប្រព័ន្ធធារាសាស្ត្រ និងផ្លូវ ជនបទ។ ខ្សែច្រវាក់តម្លៃទ្រង់ទ្រាយមូលដ្ឋាន ខ្លី  នឹងធ្វើឱ្យការចែកចាកយមានតម្លៃទាប ទោះយ៉ាងនេះក្តីការកាត់បន្ថយចំណាយនេះត្រូវតែមានការថ្លឹងថ្លែងឱ្យមាន តុល្យភាពជាមួយនឹងតម្រូវការពង្រីកនិងការធ្វើពិពិធកម្មការផលិតផងដែរ។
- **លើកកម្ពស់កសិ-អេកូឡូស៊ីនៅក្នុងផលិតកម្មស្បៀង ដើម្បីកាត់បន្ថយថ្លៃដើម បញ្ឈប់ការខូចគុណភាពដី និងបង្កើនជីជាតិដីក្នុងរយៈពេលវែង។** ចាំបាច់ត្រូវមានវិធីសាស្ត្ររយៈពេលវែងដើម្បីឆ្លើយតបទៅនឹងអស្ថិរភាពនៃអាកាសធាតុ សម្រាប់វិស័យកសិកម្មដើម្បីដោះស្រាយជាមួយនឹងវិបត្តិពាក់ព័ន្ធទាំងបីគឺ ការកើនឡើងថ្លៃធាតុចូល ការប្រែប្រួលអាកាសធាតុ និងកំណើនថ្លៃដើមរួមជាមួយនិងកង្វះខាតកម្លាំងពលកម្ម។ កំណើនតម្លៃប្រេងឥន្ទនៈនិងជីកសិកម្មអាចជាកត្តាដែលជំរុញឱ្យមានការងាកទៅរកកសិ-អេកូឡូស៊ី ថ្វីបើវានឹងត្រូវការពេលវេលា ការវិនិយោគទុកមុនលើផ្នែកបច្ចេកវិទ្យា និងសមត្ថភាពក៏ដោយ។